# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង
### រវាង តំណាងបុគ្គលិក សណ្ឋាគារ សុខាអង្គរ
### និង និយោជកនៃ សណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២០ រវាងប្រធានផ្នែកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារស្ថានភាពវិបត្តិជំងឺ Covid-19 នៅលើពិភពលោកនៅតែពុំទាន់ថមថយ ធ្វើអោយប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច និងពាណិជ្ជកម្មគ្រប់វិស័យនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងនៅតែទទួលរងនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ ជាពិសេសលើវិស័យទេសចរណ៍ និងបដិសណ្ឋាកិច្ច។ អាស្រ័យហេតុនេះយើងខ្ញុំបានសម្រេចចិត្តផ្អាកសកម្មភាពអាជីវកម្មរបស់ សណ្ឋាគារ សុខាអង្គរ ជាបណ្ដោះអាសន្ន រយៈពេលពីរ(០២)ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០២០ ។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិក បានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកចំនួន **២៣០នាក់ ស្រី ៨៨នាក់** បន្តឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែទៀត គិតចាប់ពីថ្ងៃទី ០១ ខែតុលា ដល់ **ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០**។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗសម្រាប់ធ្វើការពេញម៉ោង (៤សប្តាហ៍) ក្នុងមួយខែ៖
- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល ១០០% ព្រមទាំងប្រាក់ ឧបត្ថម្ភអាហារចំនួន ២.០០ ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក តម្រូវឲ្យធ្វើការបួន (៤) ថ្ងៃក្នុងមួយខែ នឹងទទួលប្រាក់ឈ្នួលដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។

សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.,LTD.

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការឃោគយល់នេះ ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO. LTD.

______________________

**ហេង វណ្ណះ**

**ហត្ថលេខាភាគីតំណាងនិយោជិត**

សុខ សារ៉ាយុទ្ធ ______________________

អ៊ុក សុធា ______________________ 30-09-20

វ៉ាន់ ចំណាន ______________________ Chamnan-29-09-20

ប៊ុន សាលីន ______________________ 30-09-20

កាន់ គង់ហេង ______________________ 30-09-20

គង់ សុខា______________________